ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ......001/17......គជប

# សូមគោរពជូន

## សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

ជាទីគោរពដ៏ខ្ពង់ខ្ពស់

**កម្មវត្ថុៈ** សូមគោរពជូន របាយការណ៍កិច្ចប្រជុំលើកទី៤ ស្តីពី ដំណោះស្រាយករណីអន្តរកាវីនៃការពពោះជំនួស និងសូមគោរពស្នើសុំមតិដឹកនាំដ៏ខ្ពង់ខ្ពស់ ។

**យោងៈ**

- សំណើដោះស្រាយបញ្ហាចំពោះមុខ ក្រោយការបង្ក្រាប របស់អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលទទួលបានចំណារឯកភាពពីសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ប្រសាសន៍ដឹកនាំរបស់ សម្តេចក្រឡាហោម **ស ខេង** ក្រោយជំនួបជាមួយស្ថានទូតអូស្ត្រាលី ថ្ងៃទី ២៥ ខែធ្នូ ឆ្នាំ ២០១៦។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមគោរពជម្រាបជូនសម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា ៖

នៅថ្ងៃទី ២៨ ខែធ្នូ ឆ្នាំ២០១៦ នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ មានរៀបចំកិច្ចប្រជុំមន្ត្រីជំនាញដែលជាកិច្ចប្រជុំលើកទី៤ ក្រោយពីបានបង្ក្រាបករណីអន្តរកាវីនៃការពរពោះជំនួស កាលពីថ្ងៃទី ១៨ ខែវិច្ឆិកា ឆ្នាំ២០១៦ ។សមាសភាពចូលរួមមានមន្ត្រីជាន់ខ្ពស់ជាជំនាញ ពីអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ក្រសួងការបរទេស ដើម្បីបន្តការពិភាក្សា ស្តីពីការរៀបចំបែបបបទ និងនីតិវិធីបណ្តោះអាសន្នសម្រាប់ការនាំទារកដែលកើតដោយការខ្ចីពរពោះជំនួស ទៅប្រទេសគោលដៅ ។

1. ស្ថានទូតប្រទេសសាម៉ី (អូស្ត្រាលី)
2. ក្រសួងការបរទេស
3. ក្រសួងមហាផ្ទៃ
4. អគ្គនាយកដ្ឋានអន្តោប្រវេសន៍
5. ស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ។
៦. ក្រសួងយុត្តិធម៌.
៧. ក្រសួងសង្គមកិច្ច

ចំពោះបែបទនៃការនាំទារកចេញ ត្រូវធ្វើឡើងដោយបុរសជាម្ចាស់មេជីវិត ឬ ដែលហៅថាជាឪពុក តាមរយៈការធ្វើការផ្ទៀងផ្ទាត់ DNA ។ ដូចនេះ ៖

១. **<u>អ្នកស្នើសុំ ឬឪពុក</u>** ត្រូវមានសំណុំលិខិត ដែលឯកសារនីមួយៗ មានសុពលភាពយ៉ាងយូរ ០៦ ខែ គិតត្រឹមថ្ងៃដាក់ពាក្យស្នើសុំ ។ ឯកសារ មានដូចខាងក្រោម៖

- ✓ អ្នកស្នើសុំ ត្រូវមានអាស័យដ្ឋានជាលំនៅអចិន្ត្រៃយ៍ក្នុងប្រទេសដែលមានចំណងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា និងមានវ័យមិនតិចជាង ៣០ឆ្នាំ (ចំពោះអ្នកមានសហព័ទ្ធដែលត្រូវមានការឯកភាពពីសហព័ទ្ធក្នុងការស្នើសុំកូន) និងមិនតិចជាង ៥០ ឆ្នាំ ចំពោះ អ្នកដែលនៅលីវ ឬពោះម៉ាយ (?)
- ✓ ពាក្យសុំ ដែលមានរូបថត(ក្នុងពីរខែចុងក្រោយ) និងរូបសហព័ទ្ធ (បើមាន) និងក្រយៅដៃ ដែលក្នុងនោះ បញ្ជាក់ពីគោលបំណង ការធានាអះអាងក្នុងការចិញ្ចឹមបីបាច់រក្សាកូន បានល្អរហូតពេញវ័យ
- ✓ លិខិតបញ្ជាក់ DNA ដែលធានាបិតុភាព
- ✓ លិខិតអនុញ្ញាតឲ្យសុំកូនពីអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសសាមីរបស់សាមីអ្នកស្នើសុំ
- ✓ របាយការណ៍ស្ថានភាពគ្រួសារ មានបញ្ជាក់ពីសមាជិកគ្រួសារ ដែលមានការទទួលស្គាល់ពីក្រសួងមានសត្ថកិច្ច ឬអាជ្ញាធរប្រទេសសាមី
- ✓ សេចក្តីចម្លងសំបុត្រ ឬវិញ្ញាប័នប័ត្រកំណើត របស់សាមីខ្លួនអ្នកស្នើសុំ
- ✓ សេចក្តីចម្លងលិខិតអាពាហ៍ពិពាហ៍ ឬលិខិតលែងលះ ឬលិខិតបញ្ជាក់ភាពនៅលីវ ឬលិខិតមរណភាពរបស់សហព័ទ្ធ និងភាពចាំបាច់ដែលត្រូវសុំយកកូនទៅចញ្ចឹមជាកូនរបស់ខ្លួន
- ✓ លិខិតបញ្ជាក់សុខភាពរបស់សាម៉ីខ្លួនអ្នកស្នើសុំ

ក្រុមបច្ចេកទេស បានឯកភាពគ្នាតាមនីតិវិធីដូចខាងក្រោម៖

- ✓ សំណុំលិខិត របស់សាមីអ្នកស្នើសុំ ត្រូវរៀបចំជាស្រេច និងសុំការទទួលស្គាល់ពីស្ថានទូតប្រទេសសាមី ប្រចាំនៅកម្ពុជា ភ្ជាប់ជាមួយលិខិតអះអាងរបស់ស្ថានទូតទៅលើសំណុំឯកសារ បញ្ជូនទៅក្រសួងការបរទេស ។
- ✓ ក្រសួងការបរទេសចេញ សជណ បញ្ជូនសំណុំឯកសារទៅក្រសួងមហាផ្ទៃ ។
- ✓ សម្ភាសន៍សាមីខ្លួន បញ្ជាក់ជាកំណត់ហេតុអម, ចេញ សជណ និងអនុញ្ញាតឲ្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ទិដ្ឋាការចេញឲ្យសាមីខ្លួននាំទារកចេញតាមផ្លូវច្បាប់ ។

បែបបទ និងនីតិវិធីនេះ នឹងទាមទារឲ្យបំពេញគ្រប់លក្ខ័ណ្ឌ និងប្រគល់សិទ្ធិជូនក្រសួងមហាផ្ទៃក្នុងការសម្រេចថាត្រូវអនុញ្ញាត ឬមិនអនុញ្ញាត ដោយសិក្សាយ៉ាងល្អិតល្អន់ទៅលើលទ្ធភាព និងសមត្ថភាពរបស់អ្នកស្នើសុំ ។ ករណីនេះ ងាចបើកទូលាយចំពោះអ្នកដែលមិនមាន DNA ជាឪពុក តែត្រូវមានលក្ខ័ណ្ឌ ដោយឡែក តាមច្បាប់សុំកូន ។ បែបបទ និងនីតិវិធីនេះនឹងត្រូវសូមគោរពស្នើសុំរៀបចំជា **សជណ ឬអនុក្រឹត្យ** ដើម្បីអាចអនុវត្តបណ្តោះអាសន្ន ក្នុងតំណាក់កាលដែលមិនទាន់មានច្បាប់ស្តីពី ការខ្ចីឬជួលពរពោះជំនួសនេះនៅឡើយ ។

អាស្រ័យហេតុនេះ សូមសម្តេចមេត្តាជ្រាបជារបាយការណ៍ដ៏ខ្ពង់ខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ២០១៦

**អនុប្រធានអចិន្ត្រៃយ៍**

**ជូ-ម៉ុនអេង**